# English for Study in Australia
## កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

LESSON 19– A classroom presentation

**មេរៀនទី១៩ ៖ ការធ្វើបទបង្ហាញនៅក្នុងថ្នាក់រៀន**

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

Rocky:
រ៉ុកឃី៖ និស្សិតអន្តរជាតិ
Angel:
អែនជល៖ និស្សិតអន្តរជាតិ
Katie:
ខេតធី៖ និស្សិតអន្តរជាតិ
George:
ចច ៖ និស្សិតបរទេស

**សាច់រឿង**

រ៉ុកឃី អែនជល និងខេតធី ធ្វើបទបង្ហាញអំពីលទ្ធផលរកឃើញនៃគម្រោងស្រាវជ្រាវរបស់ខ្លួន នៅក្នុងថ្នាក់រៀន។

**ព័ត៌មាន-គន្លឹះមួយចំនួនសម្រាប់ការធ្វើបទបង្ហាញ**

- សូមលោកអ្នកសរសេរអំពីអ្វីដែលលោកអ្នកត្រូវនិយាយឱ្យបានពេញលេញ និងបង្ហាញទៅឱ្យអ្នកនិយាយភាសាអង់គ្លេសជាភាសាកំណើតជួយមើល។ សូមកែសម្រួលរាល់កំហុសដែលមាន។ បន្ទាប់មក ហាត់អានឱ្យឮៗ។ ប៉ុន្តែសូមចងចាំថា លោកអ្នកមិនអាចអានអ្វីដែលលោកអ្នកសរសេរក្នុងពេលធ្វើបទបង្ហាញនោះទេ។ ការអានខ្លឹមសារនៃការធ្វើបទបង្ហាញអាចធ្វើឲ្យអ្នកស្តាប់ឆាប់ធុញថប់។
- លោកអ្នកត្រូវសម្លឹងមើលអ្នកស្តាប់ ដើម្បីឱ្យពួកគេមានការចាប់អារម្មណ៍។ ព្យាយាមមើលអ្នកស្តាប់ម្នាក់ៗយ៉ាងតិចណាស់ឱ្យបាន២ដង នៅអំឡុងពេលនៃការធ្វើបទបង្ហាញ។

- ដើម្បីជាជំនួយដល់លោកអ្នកឱ្យចងចាំនូវអ្វីដែលលោកអ្នកនឹងនិយាយ និងត្រូវនិយាយទៅតាមលំដាប់លំដោយ លោកអ្នកអាចមើលកំណត់ត្រារបស់លោកអ្នក ដែលមានសរសេរតែចំណងជើង និងពាក្យសំខាន់ៗលើក្រដាសមួយទំព័រ។ លោកអ្នកត្រូវសរសេរអក្សរឱ្យបានច្បាស់ ដើម្បីឱ្យងាយស្រួលអាន។
- សូមលោកអ្នកទទួលបាននូវជោគជ័យក្នុងការធ្វើបទបង្ហាញរបស់លោកអ្នក!

ABC Radio Australia


© RadioAustralia/AMES 2008

## ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា

| | |
|---|---|
| To draw conclusions<br>ធ្វើសេចក្តីសន្និដ្ឋាន | ធ្វើការសម្រេចចិត្ត ក្រោយពីបានសិក្សាលើទិន្នន័យ ឬស្តាប់របាយការណ៍រួច។ |
| “This talk will last about 20 minutes.” បទបង្ហាញនេះនឹងត្រូវការពេលប្រហែល ២០ នាទី។ | ការនិយាយនេះមានរយៈពេលប្រហែល២០នាទី។ |
| “I’ll hand you over to Rocky” ខ្ញុំនឹងប្រគល់នាទីនេះទៅឱ្យរ៉ុកឃី។ | “រ៉ុកឃី នឹងចាប់ផ្តើមនិយាយនៅពេលនេះ” ឬ “រ៉ុកឃីនឹងនិយាយទៅកាន់លោកអ្នកនាពេលឥឡូវនេះ”។ |
| To get the lights<br>To get the phone<br>To get the door | បើក ឬបិទភ្លើង។<br>លើកទូរស័ព្ទ។<br>បើកទ្វារ។ |

## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| anxiety | attention | audience |
| column | concerned | degree |
| extreme | findings | massage |
| (to) poll | regularly | (to) relieve |
| respondent | separation | slide |
| stress | support | variety |

ABC Radio Australia
AMES
© RadioAustralia/AMES 2008
radioaustralia.net.au
www.ames.net.au

## ២. ការហាត់រៀនភាសា លំហាត់គំរូ តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវឆ្លងកាត់ការធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best fits each space in the text below.
ចូរជ្រើសរើសពាក្យដែលសមស្របបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

Cross one box for each number, eg: ☒
សូមគូសខ្វែងនៅក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ។ ឧទាហរណ៍ ☒

1. Today I'm going to talk _________ student stress.

☐ over ☐ around ☐ with ☐ about

2. First I'll take you ____________________ our methodology.

☐ over ☐ about ☐ through ☐ into

3. ______________ that I'll discuss possible solutions

☐ Follow ☐ Following ☐ Then ☐ Next

4. And now I'll hand you ___________ to Ron who'll discuss the survey.

☐ over ☐ with ☐ for ☐ will

5. And ____________ concludes my presentation.

☐ what ☐ such ☐ that ☐ which

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

**សូរសំឡេង / θ / /t/ /ð/** ៖សូមហាត់និយាយ**ពាក្យដែលត្រូវប្រឹង**ពត់អណ្ដាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

"**The thin tin is taller than the thick tub.**"

## ៤. អាសយដ្ឋានអ៊ីនធើណែតមានប្រយោជន៍

| | |
|---|---|
| **ព័ត៌មាន ៖** ការធ្វើរបាយការណ៍ផ្ទាល់មាត់។ | http://omnibus.uni-freiburg.de/~wh2/TAidOralReport.htm |

ចម្លើយលំហាត់ទី 2: 1) about 2) through 3) following 4) over 5) that


© RadioAustralia/AMES 2008